00629600

A410/2/2

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**ការិយាល័យរដ្ឋបាល**
Office of Administration

(អបក ១២៧)

**លេខ:......៩៣១.....អ.វ.ត.ក/រប**

ថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ២០១០

សម្ងាត់ / Confidential / Confidentiel
សាធារណៈ / Public

---

**ចម្លើយតប**

**គោរពជូន:** លោកប្រធាន លោក [illegible] ចៅក្រម នៃអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក.

**គោរពជូនពី:** ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី

E.C.C.C * C.E.T.C

**ចំលងជូន:**
- ការិយាល័យសហចៅក្រមស៊ើបអង្កេត
- ការិយាល័យសហព្រះរាជអាជ្ញា
- សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី
- មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់
- អង្គភាពគាំពារជនរងគ្រោះ
- ការិយាល័យសហមេធាវីការពារក្តីជនត្រូវចោទ

**កម្មវត្ថុ:** **ចម្លើយតបទៅលើ** ‘សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០១០” និង “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០”

**យោង:** - សំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០[1] ។

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 01 / 12 / 2010
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

---

[1] ឯកសារលេខ A410

- លិខិតរបស់សហចៅក្រមស៊ើបអង្កេតឆ្លើយតប ទៅនឹងពាក្យប្ដឹងរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងនឹងការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១០[2] ។
- បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើស្ដីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០១០[3] ។
- ការជូនដំណឹងមកការិយាល័យរដ្ឋបាលតាមរយៈប្រព័ន្ធអេឡិកត្រូនិក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០ របស់អង្គបុរេជំនុំជម្រះស្ដីពីការដាក់ឯកសារ ។

1. ដោយបានធ្វើការចាត់ចែងការងាររដ្ឋបាលពាក់ព័ន្ធទៅនឹងទីតាំងដែលបានលើកឡើងដោយក្រុមមេធាវីដើមបណ្ដឹងឧទ្ធរណ៍ ការិយាល័យរដ្ឋបាលសូមធ្វើការឆ្លើយតបទៅនឹងការលើកឡើងពីកង្វល់ និងបញ្ហាទាំងឡាយដែលក្រុមមេធាវីដើមបណ្ដឹងឧទ្ធរណ៍ បានលើកឡើងនៅក្នុងសំណើរបស់ខ្លួន ទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ហើយត្រូវបានចាត់ទុកថានៅក្រៅសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ និងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយតបរបស់ចៅក្រមស៊ើបអង្កេតទៅនឹងសំណើស្ដីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០ ដូចខាងក្រោម៖

## ១. តួនាទីរបស់ការិយាល័យរដ្ឋបាលចំពោះមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី

2. ការិយាល័យរដ្ឋបាល នៃអ.វ.ត.កបាន បង្កើតអង្គភាពជនរងគ្រោះ ក្រោយមកហៅថាអង្គភាពគាំពារជនរងគ្រោះស្របតាមវិធាន១២ នៃវិធានផ្ទៃក្នុង និងបំពេញភារកិច្ច ដូចមានចែងនៅក្នុងវិធាន១២ និងវិធាន ១២ស្ទួន[4] ដែលក្នុងនោះមានភារកិច្ចមួយ គឺ ផ្ដល់នូវការគាំពារផ្នែករដ្ឋបាលដល់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ។ ដូច្នេះការិយាល័យរដ្ឋបាលបានបង្កើត អង្គភាព

---

[2] ឯកសារលេខ A410/1

[3] ឯកសារលេខ A410/2/1

[4] វិធាន ១២ និង ១២ស្ទួននៃវិធានផ្ទៃក្នុង*(វិសោធនកម្មលើកទី៥ថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០ និងវិសោធនកម្ម លើកទី៦នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)*

00629602

គាំពារជនរងគ្រោះ ដែលមានតួនាទីទទួលខុសត្រូវកិច្ចការរដ្ឋបាលពាក់ព័ន្ធនឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។

**វិធាន ១២**: ការរៀបចំ និងការប្រព្រឹត្តទៅនៃការចូលរួមរបស់ជនរងគ្រោះ

*(វិសោធនកម្មថ្ងៃទី០៩ខែកុម្ភៈឆ្នាំ ២០១០ និងវិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)*

> "... ការិយាល័យរដ្ឋបាលអាចចុះកិច្ចសន្យាជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ការិយាល័យរដ្ឋបាលក៏ផ្តល់ផងដែរនូវការគាំពារផ្នែករដ្ឋបាលដែលចាំបាច់ដល់អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងគ្រប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ។"

3. ការបំពេញភារកិច្ចរបស់ខ្លួននេះត្រូវបានកម្រិតនៅត្រឹមធនធានដែលតុលាការមាន និងភាពចាំបាច់ក្នុងការផ្តល់ការគាំទ្រនេះ។ កន្លងមកការិយាល័យរដ្ឋបាលបានខិតខំផ្តល់ការគាំទ្រនេះ និងមានការរីកចម្រើនជាច្រើន ក្នុងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយក៏មានការទាមទារមួយចំនួន របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលលើសពីលទ្ធភាពរបស់ការិយាល័យរដ្ឋបាលផងដែរ។ ភាពមានកំណត់នៃធនធានរបស់ការិយាល័យរដ្ឋបាលត្រូវបានពន្យល់ជាច្រើនដង ជូនក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់គ្នា ប៉ុន្តែកិច្ចខំប្រឹងប្រែងនេះមិនត្រូវបានទទួល និងសហការពីបុគ្គលមួយចំនួនឡើយ។

## ២. ការប្រើប្រាស់សម្ភារៈការិយាល័យ

4. កន្លងមក នៅក្នុងអំឡុងពេលសវនាការសំណុំរឿងលេខ០០១ អាគារមណ្ឌលព័ត៌មានមានតែកុំព្យូទ័រ ៣ គ្រឿងប៉ុណ្ណោះ សម្រាប់អ្នកដែលមានភារកិច្ចពាក់ព័ន្ធនឹង អ.វ.ត.ក. ដើម្បីប្រើប្រាស់ (មិនមែនទុកផ្តាច់មុខឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីណាមួយទេ)។ ចំណែកនៅឯអាគារអង្គភាពគាំពារជនរងគ្រោះនៅតុលាការវិញក៏មានកុំព្យូទ័រចំនួន ៨ គ្រឿង គឺ៖គ្រឿង នៅក្នុងបន្ទប់តូចសម្រាប់មេធាវី ៣គ្រឿងនៅក្នុងបន្ទប់C១៣១ និង៣គ្រឿងនៅក្នុងបន្ទប់C១៣២ និង២គ្រឿងនៅក្នុងបន្ទប់របស់ដើមបណ្តឹងរដ្ឋប្បវេណី C ១២៧។

5. បច្ចុប្បន្នការិយាល័យរដ្ឋបាលបានរៀបចំបន្ទប់ជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានទីតាំងនៅមជ្ឈមណ្ឌលព័ត៌មានសាធារណៈនៅក្រុងភ្នំពេញផង និងបន្ទប់លេខ C ១២៧ (នៅសាលាក្តី)ផងគឺជាការសម្របសម្រួលការងារជាច្រើនដល់មេធាវី ដូចជាចំណេញពេលវេលាធ្វើដំណើរទៅមកអនុញ្ញាតឱ្យមេធាវីបំពេញកិច្ចការ



ហ

បានច្រើន និងដោយប្រសិទ្ធភាពនិងសម្រួលដល់ការងារជួបកូនក្តីរបស់ខ្លួន។ល។ មេធាវីដែលមិនទទួលមូលនិធិពីតុលាការត្រូវបានផ្តល់ជាសម្ភារៈការិយាល័យ កុំព្យូទ័រចំនួន ១៦ គ្រឿង (៧គ្រឿង នៅជាន់ក្រោមនៃមណ្ឌលព័ត៌មាន និង៩ គ្រឿង នៅបន្ទប់C127 ក្នុងអគាររបស់តុលាការ) ដែលទុកសម្រាប់តែក្រុមមេធាវី និងមានកុំព្យូទ័រ ៦ គ្រឿងទៀត សម្រាប់ ប្រើប្រាស់ទាំងអស់គ្នា នៅបន្ទប់ប្រជុំនៅជាន់ទី១នៃអាគារមណ្ឌលព័ត៌មាន។ ដូច្នេះ មេធាវីទាំងអស់ បានទទួលសិទ្ធិពេញលេញរួចជាស្រេចក្នុងការប្រើប្រាស់កុំព្យូទ័រទាំងនៅមជ្ឈមណ្ឌលព័ត៌មានសាធារណៈនៅក្រុងភ្នំពេញ និងទាំងនៅក្នុងអគារតុលាការចំនួនសរុប ២២គ្រឿង រួមទាំងមានម៉ាស៊ីន Printers ចំនួន ០៤គ្រឿង និង Scanners ចំនួន០២ គ្រឿង ពោលគឺមានកុំព្យូទ័រច្រើនជាងមុនទ្វេរដងដោយមិនរាប់បញ្ចូលចំនួនកុំព្យូទ័រដែលប្រើប្រាស់ដោយក្រុមមេធាវីទទួលមូលនិធិពីតុលាការ និងអង្គភាពសហមេធាវីនាំមុខ។

6. ដើម្បីធ្វើបច្ចុប្បន្នភាពលើការចាត់ចែងថ្មីនេះ អង្គភាពគាំពារជនរងគ្រោះបានជូនដំណឹងដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីថាសម្ភារៈប្រើប្រាស់ទាំងអស់នេះ គឺសម្រាប់មេធាវីទាំងអស់ប្រើប្រាស់ ហើយគ្មានមេធាវីណាអាចកាន់កាប់ផ្តាច់មុខលើកុំព្យូទ័រណាមួយសម្រាប់ប្រើប្រាស់ជាអចិន្ត្រៃយ៍ឡើយ មានន័យថាជាការប្រើប្រាស់រួមក្នុងចំណោមមេធាវីទាំងអស់។ តាមការពិត ដោយផ្អែកលើធនធានដែលតុលាការមាន អង្គភាពគាំពារជនរងគ្រោះបានខិតខំជំនះរាល់ការលំបាកទាំងឡាយ ដើម្បីធានាឲ្យមាននិរន្តភាពនៃសេវាកម្មចាំបាច់ទាំងឡាយ ដល់ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងការបំពេញវិជ្ជាជីវៈរបស់ខ្លួនឲ្យបានល្អប្រសើរឡើង ក្នុងការការពារផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាអ្នកដាក់ពាក្យប្តឹងដែរ។ម្យ៉ាងវិញទៀត ការចាត់ចែងនេះក៏ផ្អែកលើលក្ខខ័ណ្ឌដែលថាអង្គភាពគាំពារជនរងគ្រោះ ទទួលបាននូវថវិកាសម្រាប់គម្រោងគាំទ្រការចូលរួម របស់ជនរងគ្រោះមានកម្រិត ប៉ុន្តែការទាមទាររបស់មេធាវីក្រុមនេះតែងតែលើសពីកម្រិតនៃធនធានដែលតុលាការមាន។

### ៣. ការប្តូរទីកន្លែង និងមូលហេតុ

7. ការិយាល័យរដ្ឋបាល បានសម្រេចរៀបចំកែសម្រួលទីកន្លែងធ្វើការរបស់បុគ្គលិករបស់អង្គភាពគាំពារជនរងគ្រោះពីមណ្ឌលព័ត៌មាននៅភ្នំពេញមកទីតាំងតុលាការ ដើម្បីឲ្យកិច្ចការរបស់អង្គភាពត្រូវបំពេញបានឆាប់រហ័សដោយគិតទៅលើភាពចាំបាច់ក្នុងការទំនាក់ទំនងជាញឹកញាប់ជាមួយផ្នែកផ្សេងៗនៃការិយាល័យរដ្ឋបាល ឬ តុលាការ និងជាការងាយស្រួលក្នុងការគ្រប់គ្រងបុគ្គលិកផងដែរ។ ការរៀបចំនេះក៏បង្កលក្ខណៈងាយស្រួលឲ្យក្រុមមេធាវីតំណាងបណ្តឹងរដ្ឋប្បវេណីប្រើប្រាស់ការិយាល័យនៅភ្នំពេញ ក្នុងការជួបជាមួយកូនក្តីរបស់ខ្លួនដែលមានចំនួនច្រើន

00629604

ដោយចៀសវាងការធ្វើដំណើរឆ្ងាយមកទីតាំងនៅចោមចៅដែលនាំឱ្យមានការលំបាកច្រើន ដល់កូនក្តីដែលភាគច្រើនជាមនុស្សចាស់ និងពិបាកធ្វើដំណើរ ងាយស្រួលក្នុងការមកប្រើប្រាស់ប្រព័ន្ធ Internet, Zylab និងប្រព័ន្ធព័ត៌មាន ផ្សេងទៀត ជាមួយក្រុមមេធាវីដ៏ទៃទៀត។

8. សម្រាប់រយៈពេលអន្តរកាលនៃការផ្លាស់ប្តូរនេះ ប្រព័ន្ធព័ត៌មានវិទ្យាទាំងនេះមានការយឺតយ៉ាវបន្តិចបន្តួច។ កន្លងមកការិយាល័យរដ្ឋបាល បានព្យាយាមពិភាក្សារកដំណោះស្រាយជាមួយផ្នែកដែលពាក់ព័ន្ធជាច្រើនលើកច្រើនសារ ដើម្បីដោះស្រាយបញ្ហានេះ។ ការិយាល័យរដ្ឋបាលបានខិតខំដោះស្រាយបញ្ហានេះរហូតដល់បានរួចរាល់ និងអាចប្រើប្រាស់ប្រព័ន្ធនេះបានដោយលក្ខណៈល្អប្រសើរ។

9. ផ្ទុយទៅវិញ មេធាវីក្រុមនេះ ដោយផ្តើមចេញពីលោកស្រីមេធាវី Silke STUDZINSKY ដែលមិនសប្បាយចិត្តនឹងវិធានការណ៍ទាំងនេះ បានធ្វើការតវ៉ាជាញឹកញាប់មកការិយាល័យរដ្ឋបាល ទោះជាមានការព្យាយាមពន្យល់ពីសំណាក់ការិយាល័យរដ្ឋបាលក៏ដោយ។ ទង្វើនេះបានបង្កឱ្យមានការរំខានជាខ្លាំងដល់អារម្មណ៍របស់បុគ្គលិកនៃអង្គភាពក្នុងការបំពេញការងាររបស់ខ្លួន។ លើសពីនេះ គាត់ប្រើប្រាស់ផ្លូវតុលាការដើម្បីទាមទារអ្វី ដែលហួលពីលទ្ធភាពរបស់ការិយាល័យរដ្ឋបាលដូចបានជម្រាបជូនខាងលើ។

10. ការិយាល័យរដ្ឋបាលបានស្វែងយល់ពីចេតនាពិតប្រាកដរបស់លោកស្រីមេធាវីរូបនេះ ហើយបានដឹងថាគាត់ធ្លាប់ប្រើប្រាស់បន្ទប់មួយ [5] នៃអង្គភាពគាំពារជនរងគ្រោះដោយផ្តាច់មុខនៅតែម្នាក់ឯង ដោយគិតតែខ្លួនឯងថា នេះជាបន្ទប់របស់ខ្លួន សម្រាប់ខ្លួន និងអ្នកហាត់ការរបស់ខ្លួនប្រើប្រាស់ប៉ុណ្ណោះ។ ចំណែកមេធាវីដ៏ទៃទៀតមិនបានកាន់កាប់បន្ទប់ដូចលោកស្រីនេះឡើយ។ តាមពិត អង្គការជំនួយផ្លូវច្បាប់នៃកម្ពុជា (LAC) បានរៀបបន្ទប់ការិយាល័យ និងបុគ្គលិកគាំទ្រ (ដោយមានមូលនិធិ DED) ជូនគាត់សម្រាប់បំពេញការងារ ប៉ុន្តែគាត់មិនបានពិចារណាប្រើប្រាស់ការិយាល័យនោះទេ តែបែរជាមកប្រើប្រាស់ទីតាំងដែលត្រូវបានកំណត់សម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទូទៅ ធ្វើជាកន្លែងអង្គុយធ្វើការអចិន្ត្រៃយ៍និងរក្សាឯកសាររបស់ខ្លួន និងអ្នកហាត់ការរបស់ខ្លួនទៅវិញ ដោយភាពអនាធិបតេយ្យ រំលោភបំពានសិទ្ធប្រើប្រាស់សម្ភារៈនិងការិយាល័យរបស់ក្រុមដ៏ទៃ។បច្ចុប្បន្ននេះមេធាវីតំនាងដើមបណ្តឹងរដ្ឋប្បវេណីមានចំនួន ១២ ក្រុម ដូច្នេះ ប្រសិនបើក្រុមមេធាវីទាំងអស់ទាមទារការប្រើប្រាស់ បន្ទប់ និងសម្ភារៈម្នាក់ចំនួនមួយ ឬក៏មួយក្រុមបន្ទប់ចំនួន ១ តើត្រូវឱ្យការិយាល័យរដ្ឋបាលដោះស្រាយ

---

[5] បន្ទប់លេខ C131 នៃអគាររបស់អង្គភាពគាំពារជនរងគ្រោះនៅឯតុលាការ។

00629605

ដោយ វិធីណា? ការិយាល័យរដ្ឋបាលមិនអាចផ្តល់បន្ទប់ឲ្យទៅគ្រប់មេធាវី ឬគ្រប់ក្រុមឡើយ ហើយក៏មិនអាចផ្តល់បន្ទប់ដល់មេធាវីដល់ក្រុមណាមួយជាពិសេសឡើយ។

11. ការផ្លាស់ប្តូរទីតាំងដែលរៀបចំដោយការិយាល័យរដ្ឋបាលនេះ គឺធ្វើក្នុងគោលដៅសុចរិត និងត្រឹមត្រូវតាមតួនាទីរបស់ខ្លួន ដើម្បីបង្កលក្ខណៈងាយស្រួល ដល់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាមេធាវីតំណាងរបស់ពួកគេជាទូទៅផង និងដល់ផ្នែករដ្ឋបាលរបស់តុលាការផង ព្រមទាំងផ្នែកផ្សេងៗរបស់តុលាការក្នុងការងារទូទៅ ។ ដូច្នេះ វាជាការផ្លាស់ប្តូរ ដែលផ្តល់ប្រយោជន៍ ដល់គ្រប់ភាគីដែលពាក់ព័ន្ធ។

### ៤. កាតព្វកិច្ច និងការរំលោភបំពានកាតព្វកិច្ចរបស់មេធាវី

12. ជាការពិត មេធាវីដែលបានចុះបញ្ជីនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចគោរពទៅតាមកាតព្វកិច្ចដែលតម្រូវដោយក្របខណ្ឌគតិយុត្ត នៃព្រះរាជាណាចក្រកម្ពុជា ដូចមានកំណត់នៅក្នុងវិធាន២២(៤) នៃវិធានផ្ទៃក្នុង [6] និងមាត្រា១នៃក្រមសីលធម៌មេធាវី ។ កាតព្វកិច្ចទាំងនេះ រួមបញ្ចូលទាំងកាតព្វកិច្ចមានលំនៅដ្ឋានវិជ្ជាជីវៈ កាតព្វកិច្ចរក្សាការសម្ងាត់ និងកាតព្វកិច្ចប្រព្រឹត្តិចំពោះគ្នាទៅវិញទៅមកដោយសហភាតរៈ ដោយការគួរសម និងមិនត្រូវធ្វើឲ្យមានការប៉ះពាល់រវាងមេធាវីគ្នាឯង។

#### ក. ការបំពានលើកាតព្វកិច្ចមានលំនៅដ្ឋានវិជ្ជាជីវៈ

13. មាត្រា១ នៃក្រមសីលធម៌នៃមេធាវី ដែលចុះបញ្ជីនៅគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតជាកាតព្វកិច្ចរបស់មេធាវីក្នុងការកំណត់ទីលំនៅវិជ្ជាជីវៈដើមនៅព្រះរាជាណាចក្រកម្ពុជា [7] ។ ទីតាំងផ្ទាល់ខ្លួននេះត្រូវប្រើប្រាស់សម្រាប់តម្កល់ និងរក្សាទុកឯកសារ ពិភាក្សាជាមួយកូនក្តី និងត្រូវតែជាទីតាំងសមស្រប ប្រកដោយសេចក្តីថ្លៃថ្នូរ និងអាចឲ្យរក្សាការសម្ងាត់វិជ្ជាជីវៈបាន។

---

[6] វិធាន២២(៤)នៃវិធានផ្ទៃ អ.វ.ត.ក. *"នៅក្នុងការបំពេញការងាររបស់ខ្លួន មេធាវីត្រូវគោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា និង បទដ្ឋាន និង ក្រមសីលធម៌វិជ្ជាជីវៈ ដែលបានទទួលស្គាល់"* ។

[7] មាត្រា ១. មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវកំណត់ទីលំនៅវិជ្ជាជីវៈដើម នៅក្នុងប្រទេសកម្ពុជា។

14. ក្នុងចំណោមមេធាវីដែលលើកឡើងនេះ មានមេធាវីបរទេសចំនួនពីររូបគឺមេធាវី Silke STUDZINSKY និងមេធាវី Lyma NGUYEN ជាពិសេសដែលមិនបានគោរពតាមមាត្រានេះ។ លោកស្រីទាំងពីរនេះគឺជាទីប្រឹក្សារបស់អង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា។ តាមការសាកសួរមន្ត្រីដែលបំរើការងារនៅអង្គការខាងលើនេះ បានបញ្ជាក់ថាអង្គការបានរៀបចំនូវទីកន្លែងធ្វើការសមរម្យ និងបុគ្គលិកគាំទ្រ នៅក្នុងទីតាំងដ៏ធំរបស់អង្គការនេះដែលស្ថិតនៅផ្ទះលេខ៥១ ផ្លូវលេខ ៦០៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ប៉ុន្តែលោកស្រីទីប្រឹក្សាទាំងពីររូបនេះបែរជាមកបង្កបញ្ហា ដល់តុលាការទៅវិញ។ នៅពេលដែលបានសួរបញ្ជាក់ពីបញ្ហានេះ លោកស្រី Silke STUDZINSKY បាននិយាយថាគាត់គ្មានទីកន្លែងសម្រាប់ធ្វើការផ្សេងឡើយ(SIC)។ តើនេះគឺជាភាពស្មោះត្រង់នៅក្នុងការសហការគ្នាឬ?

15. ដូចបានជម្រាបជូនខាងលើ ទីតាំងរបស់អង្គភាពគាំពារជនរងគ្រោះ មិនមែនផ្តល់ជាការិយាល័យអចិន្ត្រៃយ៍ជូនមេធាវីឡើយ គឺគ្រាន់តែជាកន្លែងសម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទូទៅប្រជុំរវាងមេធាវីនិងមេធាវី ជួបជាមួយកូនក្តី និងពិគ្រោះឯកសារ ទាញយកឯកសារ និងចម្លងឯកសារដែលចាំបាច់មួយចំនួនតែប៉ុណ្ណោះ។ មេធាវីត្រូវមានទីតាំងផ្ទាល់ខ្លួនសម្រាប់តម្កល់ និងរក្សាទុកឯកសារដែលពួកគាត់ទទួលបាន ដែលជាទីតាំងសមស្របប្រកបដោយសេចក្តីថ្លៃថ្នូរ និងបំពេញការងារដោយរក្សាបាននូវការរក្សាការសម្ងាត់វិជ្ជាជីវៈ និងមានលក្ខណៈវិជ្ជាជីវៈ។ ដូច្នេះ មេធាវីទាំង២ រូបនេះបានរំលោភលើមាត្រា១ នៃក្រមសីលធម៌ ដោយគ្មានលំនៅវិជ្ជាជីវៈដើមនៅព្រះរាជាណាចក្រកម្ពុជាឡើយ។

### ខ.ការប៉ះពាល់ដល់កាតព្វកិច្ចរក្សាការសម្ងាត់របស់មេធាវី

16. ក្រុមមេធាវីនេះ ដោយឈរលើមូលដ្ឋានអត្តនោម័តរបស់ខ្លួនបានយល់ថា ការចាត់ចែងទាំងអស់អំពីការផ្លាស់ប្តូរទីតាំងក្នុងការិយាល័យ ជាបច្ច័យដែលធ្វើឱ្យពួកគាត់ពិបាកក្នុងការអនុវត្តបាននូវកាតព្វកិច្ចរក្សាការសំងាត់វិជ្ជាជីវៈ។ ពួកគាត់បានលើកឡើងថា *"មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានជ្រើសរើសការរៀបចំដូច្នេះទេ។ ប៉ុន្តែប្រធានការិយាល័យរដ្ឋបាលជាអ្នកបញ្ជាឱ្យមានស្ថានភាពធ្វើការដូច្នេះ ហើយទង្វើនេះធ្វើឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្ថិតក្នុងស្ថានភាពដែលអាចបំពានករណីយកិច្ច សីលធម៌របស់ខ្លួន ដែលធ្វើឱ្យប៉ះពាល់យ៉ាងអយុត្តិធម៌ដល់សិទ្ធិជំនុំជម្រះរបស់ដើមបណ្តឹងរដ្ឋប្បវេណី"*[8]។

---

[8] កថាខ័ណ្ឌទី១៦ នៃសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០

00629607

17. ក្រុមមេធាវីនេះបន្តការយល់ឃើញបន្ថែមទៀតថា នៅក្នុងកាលៈទេសៈដែលធ្ងន់ធ្ងរបំផុតនោះ ការខកខានមិនបានកែខៃស្ថានភាពការងាររបស់ក្រុមសហមេធាវីខ្លួនអាចនាំឲ្យប្រធានការិយាល័យរដ្ឋបាលរំលោភបំពានលើវិធាន៣៥ នៃវិធានផ្ទៃក្នុង ដោយសារបានទម្លាយព័ត៌មានសម្ងាត់តាមរយៈការបង្កើត និងបន្តអនុវត្តស្ថានភាពការងារនេះ ដែលនាំឲ្យក្រុមមេធាវីខ្លួនមិនអាចបំពេញកាតព្វកិច្ចរក្សាការសម្ងាត់របស់ខ្លួនបានឡើយ។[9]

18. យោងមាត្រា៧ នៃក្រមសីលធម៌វិជ្ជាជីវៈមេធាវីចែងថា *"មេធាវីត្រូវប្រកាន់ឲ្យបានខ្ជាប់ខ្ជួនដាច់ខាតនូវអាថ៌កំបាំងវិជ្ជាជីវៈ"*។ ដូច្នេះ មេធាវីត្រូវតែគោរពកាតព្វកិច្ចនេះមិនមែនការិយាល័យរដ្ឋបាលនោះទេ។ ក្នុងខណៈនេះដែរ មេធាវីដ៏ទៃទៀត ទាំងមេធាវីទទួលមូលនិធិពី អ.វ.ត.ក និងមេធាវីអង្គការដ៏ទៃទៀតមិនមានបញ្ហាក្នុងការគ្រប់គ្រងឯកសារ និងគោរពកាតព្វកិច្ចរក្សាការសម្ងាត់របស់ខ្លួនឡើយ។ ផ្ទុយទៅវិញ ក្រុមមេធាវីនេះបែរជាយល់ថាខ្លួនពិបាករក្សាការសម្ងាត់ទៅវិញ និងមានតែការិយាល័យរដ្ឋបាលប៉ុណ្ណោះ ដែលមានភារកិច្ចក្នុងការជួយរក្សាការសម្ងាត់វិជ្ជាជីវៈរបស់ពួកគេបាន។ តាមការអនុវត្តន៍ជាក់ស្តែង មេធាវីត្រូវរក្សាទុកឯកសារដែលបោះពុម្ពចេញពីម៉ាស៊ីន Printer ដោយយកចិត្តទុកដាក់ មិនមែនដាក់រាយប៉ាយគរលើតុ និងពេលខ្លះដាក់លើឥដ្ឋបែបគ្មានសណ្តាប់ធ្នាប់ឡើយ។ លើសពីនេះទៅទៀត មេធាវីត្រូវបាន ជូនដំណឹងរួចហើយថា ទីតាំងនេះជាទីកន្លែងប្រើប្រាស់សម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទូទៅ ។ មេធាវីគួរតែប្រុងប្រយ័ត្នដោយខ្លួនឯងក្នុងការរក្សាការសម្ងាត់នេះ។ ប្រសិនបើមេធាវីមានការិយាល័យផ្ទាល់ខ្លួន និងយកឯកសារទៅប្រើប្រាស់នៅទីនោះគឺគ្មានបញ្ហាអ្វីចោទឡើយ។

19. ការលើកឡើងរបស់ក្រុមមេធាវីខាងលើ ដូចបានរៀបរាប់ជូននៅក្នុងកថាខ័ណ្ឌទី១៦ និង១៧ ខាងលើ គឺមិនសមហេតុផលឡើយ។ ការអះអាងនោះគឺថា ខ្លួនឯង មិនអាចរក្សាការសំងាត់វិជ្ជាជីវៈរបស់ខ្លួន បណ្តាលមកពីការរៀបចំការិយាល័យរបស់ការិយាល័យរដ្ឋបាល និងបានចោទប្រកាន់ការិយាល័យរដ្ឋបាលថាអាច រំលោភបំពានលើវិធាន៣៥ នៃវិធានផ្ទៃក្នុង ដោយជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះក្នុងការ រក្សាការសម្ងាត់វិជ្ជាជីវៈមេធាវី។ ការិយាល័យរដ្ឋបាលយល់ឃើញថា ការលើកឡើងទាំងនេះគឺជារឿងពីរដាច់ ដោយឡែកពីគ្នា ពោលគឺការិយាល័យរដ្ឋបាលមានកាតព្វកិច្ចដូចបានរៀបរាប់នៅក្នុងចំនុច ១ (តួនាទីរបស់ ការិយាល័យរដ្ឋបាល...) ខាងលើ ហើយការរក្សាការសម្ងាត់វិជ្ជាជីវៈជាកាតព្វកិច្ចរបស់មេធាវីខ្លួនឯង។ ការិយាល័យរដ្ឋបាលពុំមែនជាភាគី

[9] កថាខណ្ឌទី២៩ នៃសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ឯកសារលេខ A410។

នៃសំណុំរឿង០០១ និង០០២ ដូចក្រុមមេធាវីនេះទេ។ ដូច្នេះការិយាល័យរដ្ឋបាល សូមជម្រាបជូនថាក្រុមមេធាវី ត្រូវតែជាអ្នករក្សាការសម្ងាត់ដោយខ្លួនឯង។

**គ.ការរិះគន់ចំពោះប្រព័ន្ធជំនួយផ្លូវច្បាប់**

20. ក្រៅពីនេះ ក្រុមមេធាវីនេះបានរហូតដល់រិះគន់ថា "*អ.វ.ត.ក. មិនបានផ្តល់ប្រព័ន្ធជំនួយផ្លូវច្បាប់ណាមួយដើម្បីធានាថាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានតំណាងស្របតាមច្បាប់ឡើយ។ មេធាវីទាំងបីនាក់នេះ គ្មានមេធាវីបរទេស ហើយកូនក្តីនឹងមានអារម្មណ៍ស្មើភាពទៅនឹងខាងការពារក្តី ប្រសិនបើមានមេធាវីជាតិផង និងបរទេសផង*"[10]។ ការិយាល័យរដ្ឋបាលសូមជម្រាបថា កូនក្តីមានសេរីភាពក្នុងការជ្រើសរើសមេធាវីដែលខ្លួនពេញចិត្ត។ ចំពោះកូនក្តីដែលគ្មានមេធាវី គឺជាបន្ទុករបស់អ.វ.ត.ក. ក្នុងការស្វែងរកមេធាវី ជូនដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីខ្មែរមានសិទ្ធិតំណាងកូនក្តីចំពោះមុខ អ.វ.ត.ក. ដោយគ្មានមេធាវីបរទេស ផ្ទុយទៅវិញមេធាវីបរទេសត្រូវសហការជាមួយមេធាវីខ្មែរ ដោយស្មើភាពគ្នា។

21. អ.វ.ត.ក ជាតុលាការបែបព្រហ្មទណ្ឌ និងអនុញ្ញាតឱ្យមានដើមបណ្តឹងរដ្ឋប្បវេណីធ្វើការតវ៉ាក្តីដើម្បីសំណងផ្លូវចិត្ត ដោយមានការជ្រោមជ្រែងពីសង្គមស៊ីវិល។ កន្លងមកសង្គមស៊ីវិលមួយចំនួន បានផ្តល់សេវាកម្មផ្លូវច្បាប់ពេញទំហឹង ដោយមានការិយាល័យបំពេញការងារសម្រាប់មេធាវី ថវិការឧបត្ថមដល់មេធាវី និងសម្ភារៈផ្សេងៗដែលមិនត្រូវបានបង្ហាញចេញ។ ដូចនេះ ក្រុមមេធាវីដើមបណ្តឹងឧទ្ធរណ៍ទាំងនេះ មានលក្ខខណ្ឌកិច្ចសន្យាជាមួយនឹងសង្គមស៊ីវិលនោះរួចទៅហើយ ក្នុងការបំពេញតួនាទីជួយជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាបណ្តឹងរដ្ឋប្បវេណីនៃ អ.វ.ត.ក នេះមួយចំនួន។ ដោយឡែកចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលមិនទាន់មានមេធាវីតំណាង គឺត្រូវការជំនួយពី អ.វ.ត.ក ជាចាំបាច់ ទើប អ.វ.ត.ក សម្រេចផ្តល់សេវាកម្មមេធាវីបន្ថែមទៀត និងមានភារៈកិច្ចក្នុងការផ្តល់ទីកន្លែងការងារប្រចាំការ ដូចដែលក្រុមមេធាវីដែលបានទទួលមូលនិធិ និងការគាំទ្រពអង្គការដទៃទៀត។ ម្យ៉ាងទៀតអង្គភាពគាំពារជនរងគ្រោះ ក៏បានជួយសម្រួលនូវលក្ខខណ្ឌការងារ ទាំងផ្នែកសម្ភារៈ និងទីកន្លែងដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទូទៅដូចបានរៀបរាប់នៅក្នុងចំនុចទី២ស្តីពីការប្រើប្រាស់សម្ភារៈការិ

---

[10] កថាខ័ណ្ឌទី៨ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០១០

00629609

យាល័យខាងលើ(ក្នុងកថាខណ្ឌទី៤ខាងលើ)។ បច្ចុប្បន្ននេះ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ សុទ្ធតែមានមេធាវី គឺគ្មានការរំលោភលើវិធានផ្ទៃក្នុងនៃ អ.វ.ត.ក.ឡើយ។

## ឃ. ការប្រព្រឹត្តមិនត្រឹមត្រូវចំពោះមេធាវីទទួលមូលនិធិពីតុលាការ

22. ដោយអះអាងថា *"កូនក្តីរបស់មេធាវីទាំងបីរូបទទួលមូនិធិតុលាការមិនមានមេធាវីបរទេសតំណាងឡើយ ទោះបីជនរងគ្រោះបានលើកឡើងជាច្រើនលើកច្រើនសាថា ពួកគាត់មានអារម្មណ៍ទទួលបានការយកចិត្តទុកដាក់ស្មើគ្នានឹងខាងភាគីចុងចោទច្រើនជាងមុន បើសិនពួកគាត់(កូនក្តីទាំងនោះ)មានមេធាវីជាតិផង និង បរទេសតំណាងផង"* [11] ក្រុមមេធាវីដើមបណ្តឹងឧទ្ធរណ៍នេះ ដូចជាបានដឹងយ៉ាងច្បាស់ពីអារម្មណ៍របស់កូនក្តីចំពោះមេធាវីរបស់ពួកគេ(មេធាវីទទួលមូលនិធិពីតុលាការ)។ ពោលគឺហាក់បីដូចជាបានសាកសួរកូនក្តីអ្នកដ៏ទៃ ពីការតំណាងដោយមេធាវីរបស់ពួកគេដោយពុំមានការអនុញ្ញាតពីមេធាវីរបស់ពួកគេនោះទេ។

23. ការលើកឡើង ក៏ដូចជាសកម្មភាពបែបនេះ ជាការបង្កការប៉ះពាល់ដល់ក្របខណ្ឌច្បាប់ដែលអនុញ្ញាតឱ្យមេធាវីខ្មែរអាចប្រកបវិជ្ជាជីវៈម្នាក់ឯងចំពោះមុខអ.វ.ត.ក.(វិធាន២២នៃវិធានផ្ទៃក្នុង) និងជាការប្រមាថដល់សមត្ថភាពរបស់មេធាវីទាំងបីរូប[12] ក្នុងការបំពេញភារកិច្ចជូនកូនក្តីរបស់ខ្លួន ដែលការលើកប្រយោគបែបនេះនឹងធ្វើឱ្យកូនក្តីបាត់ជំនឿលើមេធាវីខ្មែរទាំងបីដែលជាសហភាតាដូចគ្នា ពោលគឺវាជាការខ្វះការគោរពគ្នាទៅវិញទៅមករវាងមេធាវី និងមេធាវី។ លើសពីនេះទៅទៀត ក្រុមមេធាវីម្ចាស់បណ្តឹងឧទ្ធរណ៍នេះមិនដែលមកពីគ្រោះយោបល់ឬសុំការអនុញ្ញាតពីក្រុមមេធាវីទទួលមូលនីធិពីតុលាការ ដើម្បីប្រើប្រាស់ព័ត៌មានដែលពាក់ព័ន្ធ នឹង មេធាវីទាំងបីរូបក្នុងសំណើនិងបណ្តឹងឧទ្ធរណ៍របស់ខ្លួនឡើយ។ នេះគឺជាការបំពានសិទ្ធិរបស់មេធាវីទាំងបីរូប ដែលទទួលមូលនិធិពីតុលាការនេះ។ ទង្វើទាំងនេះគឺជាការបំពានយ៉ាងធ្ងន់ធ្ងរលើមាត្រា២៥ នៃក្រមសីលធម៌វិជ្ជាជីវៈមេធាវីដែលហាមមិនអោយមានការបំពានគ្នាទៅវិញទៅមក ដែលបានបញ្ញត្តិថា *"គ្រប់ទំនាក់ទំនងរវាងមេធាវីគ្នាឯង*

---

[11] កថាខណ្ឌទី៨ និង៩ នៃបណ្តឹងឧទ្ធរណ៍ ឯកសារលេខ A410/2/1។

[12] ដើម្បីធានាឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានការតំណាងគ្រប់គ្នាដោយមេធាវី ការិយាល័យរដ្ឋបាលបានចុះកិច្ចសន្យាជាមួយមេធាវី ពីររូប និងក្រោយមកថែម ១រូបទៀត ដែលជាចំនួនចាំបាច់ដើម្បីតំណាងអ្នកដែលគ្មានតំណាង និងតាមការណែនាំរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។

00629610

*ត្រូវប្រព្រឹត្តឡើង ក្នុងស្មារតីនៃសហភាតរភាពសមរម្យ និងគួរសមជានិច្ច។ ក្នុងការគោរពផលប្រយោជន៍អតិថិជនរបស់ខ្លួន មេធាវីមិនត្រូវធ្វើអ្វីដែលអាចនឹងនាំឱ្យខូចខាតដល់សហភាតារបស់ខ្លួនឡើយ។”*

24. ការិយាល័យរដ្ឋបាលយល់ឃើញថា ការលើកឡើងរបស់ក្រុមមេធាវីមេធាវីដើមបណ្តឹងឧទ្ធរណ៍(ក្នុងសំណើ និងបណ្តឹងឧទ្ធរណ៍)នេះ គឺមានលក្ខណៈរើសអើង និងមិនបានយល់ច្បាស់ពី តួនាទីរបស់ខ្លួនក្នុងនាមជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ការងាររបស់ពួកគាត់គឺត្រូវធ្វើយ៉ាងណាអោយក្លាយជាតំណាងដ៏ល្អ និងផ្តល់នូវតម្រូវការចំពោះកូនក្តីរបស់ខ្លួនឯណោះទេ។ មិនគួរមកចាំសង្កេត ឬធ្វើការវាយតម្លៃ ពីតម្រូវការរបស់កូនក្តីរបស់ក្រុមមេធាវីដទៃ និងមេធាវីរបស់ពួកគេឡើយ។ ការងារទាំងនេះ គួរតែជាការងាររបស់កូនក្តីរបស់មេធាវីក្រុមនិមួយៗ ឬជាកិច្ចការដែលអង្គភាពគាំពារជនរងគ្រោះ ជាអ្នកវាយតម្លៃ និងរកដំណោះស្រាយអោយពួកគាត់ទើបត្រឹមត្រូវ។

### ខ. ការរំខានដល់អង្គភាពគាំពារជនរងគ្រោះ និងមេធាវីដ៏ទៃទៀត

25. បន្ទាប់ពីការដូរទីតាំងការិយាល័យមក លោកស្រីSilke តែងតែទាក់ទង ជាញឹកញ៉ាប់មកការិយាល័យរដ្ឋបាល ដោយមកជួបផ្ទាល់ក្តី និងសរសេរអ៊ីមែល ដោយសរសេរអ៊ីមែលទៅចៅក្រមទាំងអស់របស់អ.វ.ត.ក ប្តឹងទៅការិយាល័យសហចៅក្រមស៊ើបអង្កេត និងពេលនេះប្តឹងទៅអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក. ទៀត។ សកម្មភាពនេះ ក្លាយជាការរំខានដល់ការិយាល័យរដ្ឋបាល ទោះជាត្រូវបានពន្យល់ថាតម្រូវការនេះវាលើសពីអ្វីដែលការិយាល័យរដ្ឋបាលអាចធ្វើបាន។

26. លើសពីនេះទៅទៀត ការប្រើប្រាស់ទីកន្លែងដែលផ្តល់ជូនដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទូទៅ ក៏ត្រូវបានរំខានដោយមេធាវីរូបនេះ។ គាត់បានយកទីកន្លែងប្រើប្រាស់រួមមានតុ និងកំព្យូទ័រពី ២ ទៅ ៣គ្រឿង ប្រើប្រាស់ជាអចិន្ត្រៃយ៍។ ពេលមេធាវី និងជំនួយការមេធាវីផ្សេងមកប្រើប្រាស់ មិនមានកុំព្យូទ័រប្រើប្រាស់គ្រប់គ្រាន់នាំឲ្យមានការមិនសប្បាយចិត្ត។ ប្រសិនបើក្រុមមេធាវី Silke ប្រើប្រាស់ទីតាំងដែលផ្តល់ឲ្យដោយ អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា និងចេះគោរពសិទ្ធិរបស់អ្នកដ៏ទៃ វានឹងនាំឲ្យគ្មានបញ្ហារំខានដល់អ្នកដ៏ទៃឡើយ។ អាកប្បកិរិយាបែបនេះ គួរត្រូវបានកែប្រែ។

00629611

## សំណូមពរ

ឆ្លងតាមការបកស្រាយខាងលើ ការិយាល័យរដ្ឋបាលសូមស្នើដល់ លោកប្រធាន លោក លោកស្រីចៅក្រមនៃអង្គបុរេជំនុំជម្រះ មេត្តាជ្រាប និងពិចារណាលើ ធនធានដែលការិយាល័យរដ្ឋបាលមាន ជាជាងទៅលើផលប្រយោជន៍ឯកជនរបស់ក្រុមមេធាវីមួយក្រុមតូច និងសូមស្នើដូចតទៅ៖

១. បដិសេធបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០១០ ដែលលើកឡើងដោយក្រុមមេធាវីនេះ។

២. តម្កល់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១០។

៣. តម្រូវឲ្យមេធាវីទាំងនេះ ទៅធ្វើការនៅតាមការិយាល័យផ្ទាល់ខ្លួនគឺលំនៅដ្ឋានវិជ្ជាជីវៈ ឬអង្គការដែលផ្តល់មូលនិធិជូនពួកគាត់។

៤. តម្រូវឲ្យមេធាវីទាំងនេះគោរពតាមក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន និង

៥. គោរពតាមការរៀបចំសេវាជូនដោយការិយាល័យរដ្ឋបាល និងឈប់បង្កការរំខានដល់ការចាត់ចែងកិច្ចការរដ្ឋបាលរបស់ការិយាល័យរដ្ឋបាលចាប់ពីពេលនេះតទៅ។

សូម លោកប្រធាន លោក លោកស្រីចៅក្រម នៃអង្គបុរេជំនុំជម្រះមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។